# អ្វីទៅជាការសិក្សាស្រាវជ្រាវដើម្បីផ្ទៀងផ្ទាត់ទ្រឹស្តីមុនៗ ឬទ្រឹស្តីមានស្រាប់?

ដោយបណ្ឌិត វង់ សំអូន
ជំនួយការខុទ្ទកាល័យរាជបណ្ឌិត្យសភាកម្ពុជា

ក្រុមទស្សនវិទូ ដែលនិយមលើការសិក្សាស្រាវជ្រាវដើម្បីផ្ទៀងផ្ទាត់ទ្រឹស្តីពីមុនៗ (Postpositivist) បានបញ្ជាក់ថា រាល់ចំណេះដឹង ឬទស្សនដែលមានស្រាប់ទាំងអស់មិនប្រាកដថាត្រឹមត្រូវ១០០%នោះទេ។ អ្នកសិក្សាស្រាវជ្រាវ ឬអ្នកនិពន្ធសៀវភៅផ្នែកវិទ្យាសាស្ត្រសង្គមបានប្រមូល និងប្រើប្រាស់ព័ត៌មានឬទិន្នន័យនៅក្នុងសម័យកាលណាមួយដែលពួកគេបានឆ្លងកាត់ ឬបានជួបប្រទះដើម្បីចងក្រងជាឯកសារទុកឱ្យមនុស្សជំនាន់ក្រោយៗសិក្សារៀនសូត្រ។ នៅក្នុងដំណើរនៃការប្រមូលព័ត៌មាន និងចងក្រងសៀវភៅទាំងនោះ ក្រុមទស្សននិយមលើការសិក្សាស្រាវជ្រាវដើម្បីផ្ទៀងផ្ទាត់ទ្រឹស្តីបានចោទជាសំនួរមួយចំនួនថា តើការប្រមូលទិន្នន័យនេះមានអ្វីមកអះអាង ថាពិតជាសុក្រិត១០០%ដែរឬទេ? មានអ្វីបញ្ជាក់ថាសុក្រិត១០០%? តើការសរសេរនោះពិតជាផ្អែកលើទិន្នន័យដែលបានប្រមូលនោះ១០០%ដែរឬទេ? មានអ្វីមកបញ្ជាក់ថាពិតជាធ្វើតាមនោះ១០០%? តើទិន្នន័យទាំងនោះពិតជាអាចប្រើប្រាស់បានគ្រប់សម័យកាល និងគ្រប់ពេលវេលាបានដែរឬទេ? ហើយមានអ្វីមកអះអាងបញ្ជាក់?

យោងតាមសំណួរទាំងអស់នេះហើយបានធ្វើឱ្យទសន្សនវិទូក្រុមនេះ មិនជឿជាក់លើកទ្រឹស្តីដែលបានបង្កើតឡើងរួចហើយថាពិតជាត្រឹមត្រូវ១០០%។ ដូច្នេះទស្សនវិទូក្រុមនេះបានធ្វើការសិក្សាស្រាវជ្រាវឡើងវិញដើម្បីផ្ទៀងផ្ទាត់ទ្រឹស្តីទាំងនោះ ឬធ្វើបច្ចុប្បន្នភាពទ្រឹស្តីទាំងនេះថាតើពិតកម្រិតណា ឬអាចប្រើប្រាស់បាននាពេលបច្ចុប្បន្នកម្រិតណា និងត្រូវបន្ថែមអ្វីខ្លះលើចំណុចខ្វះខាតទាំងនោះ។ អ្នកសិក្សាស្រាវជ្រាវទាំងអស់ត្រូវស្វែងយល់ឱ្យច្បាស់ថា***រាល់ការសិក្សាស្រាវជ្រាវទាំងឡាយណាដែលធ្វើឡើង ដើម្បីផ្ទៀតផ្ទាត់ទ្រឹស្តីដែលមានស្រាប់គឺត្រូវប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវបែបបរិមាណវិស័យតែប៉ុណ្ណោះ***។

ទស្សនវិទូក្រុមនេះបានកំណត់គោលវិធីសិក្សាស្រាវជ្រាវ តាមបែបបរិមាណវិស័យតែប៉ុណ្ណោះ ដើម្បីសិក្សាស្រាវជ្រាវផ្ទៀងផ្ទាត់លើទ្រឹស្តីដែលមានស្រាប់។ នេះមានន័យថា បញ្ហាក្នុងប្រធានបទសិក្សាស្រាវជ្រាវគឺផ្តោតសំខាន់លើការលើកយកទ្រឹស្តីណាមួយដែលអ្នកសិក្សាស្រាវជ្រាវចង់ដឹង ចង់បង្កើតចំណេះដឹងថ្មី ឬចង់បានព័ត៌មានបន្ថែម ដើម្បីធ្វើការសិក្សាស្រាវជ្រាវផ្ទៀងផ្ទាត់ ឬធ្វើបច្ចុប្បន្នភាពទ្រឹស្តីនោះ ឬការសិក្សាស្រាវជ្រាវដើម្បីបង្កើតចំណេះដឹងថ្មីចេញពីទ្រឹស្តីដែលមានស្រាប់ ដោយធ្វើឡើងតាមរយៈការផ្ទៀងផ្ទាត់ជាមួយក្រុមគោលដៅនាពេលបច្ចុប្បន្នដែលមានបរិមាណ ឬចំនួនច្រើនរហូតដល់រាប់រយ ឬរាប់ពាន់នាក់។

មូលហេតុចម្បង ដែលក្រុមនេះបានកំណត់យកគោលវិធីសិក្សាស្រាវជ្រាវបែបបរិមាណវិស័យដើម្បីធ្វើការផ្ទៀងផ្ទាត់ទ្រឹស្តីដែលមានស្រាប់ ពីព្រោះការផ្ទៀងផ្ទាត់ទាមទារឱ្យធ្វើជាមួយក្រុមគោលដៅដែលមានចំនួន ឬបរិមាណច្រើននាក់ (មិនអាចធ្វើជាមួយក្រុមគោលដៅមួយក្រុមតូច ឬ២-៣នាក់បានឡើយ)។ លើសពីនេះទៀត ទស្សនវិទូក្រុមនេះបានធ្វើឱ្យទ្រឹស្តីដែលកប់ងាប់នៅក្នុងសៀវភៅមានជីវិតរស់រៀនឡើងវិញតាមរយៈការសិក្សាស្រាវជ្រាវផ្ទៀងផ្ទាត់ និងការធ្វើបច្ចុប្បន្នភាពទ្រឹស្តីទាំងនោះឡើងវិញ។

ឧទាហរណ៍ យោងតាមទ្រឹស្តីលោក ហាវ៉ាត ហ្គាដន័រ (Havard Gardner) បានបញ្ជាក់ថា“ នៅក្នុងថ្នាក់រៀនដែលមានសិស្ស២០-៣០នាក់ នៅពេលពួករៀនប្រធានបទណាមួយ ហើយចុងបញ្ចប់នៃការរៀនប្រធានបទនោះ ពួកគេទទួលបានចំណេះដឹងដូចគ្នា (បើមាន៥ចំណុច សិស្សទាំងអស់ចេះបាន៥ចំណុចដូចៗគ្នា) ការរៀនបែបនេះមិនមែនហៅថាការរៀននោះទេ ប៉ុន្តែគេហៅថា ការចម្លង ឬថាតាមគ្រូសុទ្ធសាធ ពីព្រោះសិស្ស២០-៣០នាក់ដែលមានបទពិសោធន៍ផ្សេងៗគ្នា អាយុបញ្ញាផ្សេងៗគ្នាមិនអាចទទួលបានទទួលបាន៥ចំណុចដូចគ្នានៅពេលចុងបញ្ចប់នៃមេរៀននោះទេ។” នេះមានន័យថា សិស្សទាំងអស់នោះមិនបានយកបទពិសោធន៍ ឬចំណេះដឹងដែលពួកគេមានលើប្រធានបទនោះដើម្បីចែករំលែកជាមួយមិត្តរួមថ្នាក់នោះទេ គឺពួកគេអង្គុយស្តាប់តែគ្រូទេសនាតែម្នាក់ឯងទើបចុងក្រោយទទួលបានចំណេះដឹងដូចៗគ្នា។

អ្នកសិក្សាស្រាវជ្រាវចង់ផ្ទៀងផ្ទាត់ ឬធ្វើបច្ចុប្បន្នភាពទ្រឹស្តីនេះ ថាតើក្រុមគោលដៅនាពេលបច្ចុប្បន្នគេឯកភាពលើទ្រឹស្តីនេះដែរឬទេ ឬចង់ស្វែងយល់ដើម្បីបង្កើតចំណេះដឹងថ្មីពីទ្រឹស្តីនេះ។ ដូច្នេះអ្នកសិក្សាស្រាវជ្រាវបានកំណត់បញ្ហាចេញពីទ្រឹស្តីនេះ "ផលប៉ះពាល់នៃកង្វះខាតការចូលរួមក្នុងសកម្មភាពរៀនរបស់សិស្សលើលទ្ធផលការសិក្សា៖ ដំណើរឆ្ពោះទៅរកសិស្សមជ្ឈមណ្ឌល។” បញ្ហានៅក្នុងប្រធានបទនេះ បានបង្ហាញយ៉ាងច្បាស់ពីការទាញយកទ្រឹស្តីមកសិក្សាដើម្បីផ្ទៀងផ្ទាត់ ឬធ្វើបច្ចុប្បន្នភាព។ ដូច្នេះការសិក្សាស្រាវជ្រាវនេះបានចូលក្រុមទស្សននិយមការសិក្សាស្រាវជ្រាវដើម្បីផ្ទៀងផ្ទាត់ទ្រឹស្តី តាមរយៈការប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវបរិមាណវិស័យ។

**តារាងទី១៖ ការសិក្សាស្រាវជ្រាវដើម្បីផ្ទៀងផ្ទាត់ទ្រឹស្តីពីមុនៗ**

| | |
|---|---|
| ទ្រឹស្តី | ការរៀនពិតប្រាកដគឺជាការរៀនដែលសិស្សម្នាក់ៗមានឱកាសបង្ហាញពីបទពិសោធន៍ ឬចំណេះដឹងដែលខ្លួនមានលើប្រធានបទដែលកំពុងសិក្សា ហើយពួកគេបានរៀនពីគ្នាទៅវិញទៅមក (មិនមែនរៀនស្តាប់ពីគ្រូតែម្នាក់នោះទេ) |
| ប្រធានបទ | ការសិក្សាពីប្រសិទ្ធភាពនៃការចូលរួមក្នុងសកម្មភាពរៀនរបស់សិស្សលើលទ្ធផលការសិក្សា៖ ដំណើរឆ្ពោះទៅរកការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល |

ឧទាហរណ៍ លោក ចន ឌូអ៊ី (John Dewey) អ្នកទស្សវិទូ និងក៏ជាអ្នកឯកទេសចិត្តវិទ្យាជនជាតិអាមេរិចបានបញ្ជាក់ថា "សិស្សរៀនតាមរយៈការធ្វើ"។ ក្នុងករណីនេះ ប្រសិនបើអ្នកសិក្សាស្រាវជ្រាវចង់ផ្ទៀងផ្ទាត់ទ្រឹស្តី ឬធ្វើបច្ចុប្បន្នភាពទ្រឹស្តីនេះ ពួកគេអាចបង្កើតបញ្ហា ឬប្រធានបទចេញពីទ្រឹស្តីនេះបាន "ការឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃការរៀនតាមរយៈការធ្វើលើលទ្ធផលនៃការសិក្សារបស់សិស្ស៖ការជំរុញការប្រើប្រាស់បំណិនសម្បទា"

**តារាងទី២៖ ការសិក្សាស្រាវជ្រាវដើម្បីផ្ទៀងផ្ទាត់ទ្រឹស្តីពីមុនៗ**

| | |
|---|---|
| ទ្រឹស្តី | សិស្សរៀនតាមរយៈការធ្វើ |
| ប្រធានបទ | ការឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃការរៀនតាមរយៈការធ្វើលើលទ្ធផលនៃការសិក្សារបស់សិស្ស៖ការជំរុញការប្រើប្រាស់បំណិនសម្បទា |

**តារាងទី៣៖ ជាតុគោលក្នុងទស្សននិយមផ្តោតលើការសិក្សាស្រាវជ្រាវផ្ទៀងផ្ទាត់ទ្រឹស្តី**




ជារួម ក្រុមទស្សនវិទូដែលនិយមការសិក្សាស្រាវជ្រាវដើម្បីបង្កើតចំណេះដឹងថ្មីចេញពីទ្រឹស្តីដែលមានពីមុនៗ ឬចេញពីទ្រឹស្តីដែលមានស្រាប់ បានប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបបរិមាណវិស័យតែប៉ុណ្ណោះ។ ទស្សនវិទូក្រុមនេះមានជំនឿជឿជាក់ថា រាល់ទ្រឹស្តីពីដែលបានបង្កើតឡើងពីមុនៗគឺមិនប្រាកដថាត្រឹមត្រូវ១០០%នោះឡើយ ដោយហេតុផលមួយចំនួនដូចជា៖ (១) ទ្រឹស្តីទាំងនោះត្រូវបានបង្កើតក្នុងសម័យកាលណាមួយ ដូច្នេះទ្រឹស្តីទាំងនោះមិនប្រាកដថាអាចនូវប្រើប្រាស់បានទាំងស្រុង ឬបានកម្រិតណាមួយនោះទេនាពេលបច្ចុប្បន្ន (ប្រសិនបើយើងមើលដើមឈើមួយនៅពេលខុសគ្នា-ម្សិលមិញ និងថ្ងៃនេះ ដើមឈើក៏មានភាពខុសគ្នា ហើយការយល់ឃើញរបស់យើងក៏ខុសគ្នាដែរ) (២) រាល់លទ្ធផលការសិក្សាស្រាវជ្រាវមុនៗទាំងអស់មិនប្រាកដថាពិត១០០% ពីព្រោះអ្នកស្រាវជ្រាវអាចប្រើប្រាស់ការយល់

ឃើញផ្ទាល់ខ្លួននៅក្នុងកម្រិតណាមួយ ដែលវាអាចផ្ទុយពីការពិត និងជាហេតុធ្វើឱ្យប្រាស់ចាកក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ ទោះបីជាមានគណៈកម្មការត្រួតពិនិត្យក៏ដោយ ដោយសារតែពួកគេមិនបាននៅត្រួតពិនិត្យជាប់ជាមួយអ្នកសិក្សាស្រាវជ្រាវគ្រប់ពេលវេលានៅពេលប្រមូលទិន្នន័យ ឬនៅពេលសរសេរនោះឡើយ ពួកគេគ្រាន់តែត្រួតពិនិត្យនៅពេលលទ្ធផលនៃការសិក្សាស្រាវជ្រាវបានសរសេរចប់សព្វគ្រប់តែប៉ុណ្ណោះ និង(៣) ទ្រឹស្តីដែលបានបង្កើតឡើងនៅក្នុងតំបន់ណាមួយ ពេលវេលាណាមួយ ឬស្ថានភាពណាមួយ មិនប្រាកដថាអាចយកមកធ្វើទូទៅកម្មបានគ្រប់ទីកន្លែងនោះឡើយ។ នេះជាការភាន់ច្រឡំដែលអាចកើតមានឡើងដល់ប្រតិបត្តិករ ជាពិសេសប្រតិបត្តិករដែលមិនពុំទាន់មានបទពិសោធន៍ ឬមានបទពិសោធន៍តិចតួចលើការសិក្សាស្រាវជ្រាវដោយពួកគេព្យាយាមអនុវត្តទ្រឹស្តីនោះនៅគ្រប់កាលៈទេសៈ និងគ្រប់ទីកន្លែង។ ដូច្នេះ មុនយកទ្រឹស្តីនោះទៅអនុវត្តនៅកន្លែងណាមួយ ឬជាមួយក្រុមណាមួយ គួរធ្វើការសិក្សាស្រាវជ្រាវផ្ទៀងផ្ទាត់ទ្រឹស្តីនោះជាមុនសិន ថាតើក្រុមគោលដៅនៅកន្លែងនោះ ពួកគេឯកភាពកម្រិតណា ឬមិនឯកភាពកម្រិតណាលើទ្រឹស្តីនោះ ទើបការអនុវត្តទទួលបានប្រសិទ្ធភាពខ្ពស់។

ដូច្នេះ រាល់ការសិក្សាស្រាវជ្រាវទាំងឡាយណាដែលបានផ្តោតសំខាន់លើការផ្ទៀងផ្ទាត់ទ្រឹស្តី នោះមានន័យថា អ្នកសិក្សាស្រាវជ្រាវប្រធានបទនោះគឺចូលក្នុងពួកក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវដើម្បីផ្ទៀងផ្ទាត់ទ្រឹស្តីដែលមានស្រាប់។ អ្នកសិក្សាស្រាវជ្រាវគួរកត់សម្គាល់ផងដែរថា សំណួរដំបូងដែលគេសួរនៅក្នុងការសិក្សាស្រាវជ្រាវបែបគរុសភា (Academic research)នោះគឺតើបញ្ហាដែលអ្នកសិក្សាកំពុងសិក្សាស្រាវជ្រាវនោះផ្តោតលើទស្សននិយមនៃការសិក្សាស្រាវជ្រាវមួយណា? ***ក្នុងករណីអ្នកសិក្សាស្រាវជ្រាវឆ្លើយសំណួរនេះមិនរួច នោះមានន័យថា អ្នកសិក្សាស្រាវជ្រាវក៏មិនដឹងថាតើការសិក្សាស្រាវជ្រាវនេះត្រូវប្រើគោលវិធីសិក្សាស្រាវជ្រាវអ្វីនោះទេ ដើម្បីស្វែងរកដំណោះស្រាយ ឬចម្លើយ ហើយជាលទ្ធផលអាចធ្វើឱ្យការសិក្សាស្រាវជ្រាវត្រូវធ្វើឡើងដោយមិនគោរពតាមគោលការណ៍ស្រាវជ្រាវបែបវិទ្យាសាស្ត្រ។***

## ឯកសារយោង

Babbie, E. (1995). The practice of social research (7th Ed.). Wadsworth publishing, California, USA

Creswell, W.J., & Creswell, D.J. (2018). Research Design: Qualitative, quantitative, and mixed methods approaches. (5th Ed.). SAGE publication

Cronk, C.B. (2008). How to use SPSS: A step-by-step guide to analysis and interpretation. (5th Ed.). Pyrezak publishing, California, USA

Kerlinger, N.F. & Lee, B.H. (2000). Foundation of behavioral research (4th Ed.). Thomson learning, USA